# Living the Lotus

Buddhism in Everyday Life

New Year's Issue


New Year's Message

## សំដៅទៅជាអ្វីដែលអស្ចារ្យ


ព្រះគ្រូនីវ៉ាណុ នីជិកុ

ព្រះប្រធានរីហ្សូកូសេកៃ




### យើងខ្ញុំទទួលដឹងឮថាទីនេះជាកន្លែងប្រតិបត្តិព្រះធម៌ (Dojo) យើងខ្ញុំនឹងព្យាយាមប្រតិបត្តិព្រះធម៌ដោយសេចក្តីរីករាយ

សូមជូនពរឆ្នាំថ្មី

ច្បាប់ជម្ងឺឆ្លងថ្មីបានប្តូរវីរុសប្រភេទថ្មីកូរ៉ូណាទៅដាក់ក្នុង<ប្រភេទទាំង៥>ហើយបានធ្វើឱ្យសេចក្តីបារម្ភនិងការភិតភ័យនៃមនុស្សម្នាទាំងឡាយបានចុះថយខ្លះៗចំនួនអ្នកពាក់ម៉ាស់ក៏ចុះតិចទៅៗដែរ។ក៏ប៉ុន្តែទោះជាដូច្នេះក្តីក៏នៅក្នុងកាលៈទេសៈបែបនេះនៅតែមានអ្នកដែលមានសេចក្តីព្រួយបារម្ភខ្លះៗនៅឡើយដែរ។ជាពិសេស ពីថ្ងៃនេះទៅមុខទៀត យើងត្រូវតែគិតទៅដល់និងមានសមានចិត្តចំពោះអ្នកដែលមានវ័យចំណាស់ឬអ្នកដែលមានជម្ងឺរ៉ាំរ៉ៃនិងអ្នកដែលមិនបានចាក់វ៉ាក់សាំងការពារ។

នៅប្រទេសជប៉ុនគេបានរកឃើញអ្នកដែលឆ្លងកូរ៉ូណាជាដំបូងនៅខែមករាឆ្នាំ២០២០។ មុននោះនៅខែវិច្ឆិកាឆ្នាំ២០១៩ខ្ញុំព្រះករុណាអាត្មាភាពបានសរសេរនៅក្នុង “គោលដៅសម្រាប់ឆ្នាំ២០២០” ថា “ឆ្ពោះទៅរកខួបគម្រប់១០០ឆ្នាំនៃសមាគមរីស្សូកូសេកៃ យើងម្នាក់ៗតោងតែប្រកាន់ស្មារតីថា<កន្លែងដែលយើងកំពុងតែមានវត្តមាននេះគឺជាកន្លែងប្រតិបត្តិព្រះធម៌(Sokuze Dojo)> ហើយតោងតែសងគុណដល់ទីនោះ” ។

នៅក្នុងអម្លុងពេលដែលកូរ៉ូណាកំពុងតែរាត ត្បាតខ្លាំងហើយមនុស្សម្នាក់ៗខំសម្រួមនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ យើងទាំងអស់គ្នាក៏យល់ច្បាស់ថាតើស្មារតី “កន្លែង

ដែលយើងកំពុងតែមានវត្តមាននេះគឺជាកន្លែងប្រតិបត្តិព្រះធម៌ (Sokuze Dojo) ” នេះមានសារសំខាន់ប៉ុនណា។

យើងមិនចាំបាច់គិតអ្វីច្រើនទេគឺថាស្មារតី “កន្លែងដែលយើងកំពុងតែមានវត្តមាននេះគឺជាកន្លែងប្រតិបត្តិព្រះធម៌(Sokuze Dojo) ” មានចែងនៅល្បះដើមដំបូងគេក្នុងកណ្ឌព្រះធម៌បៃតងត្រង់ជំពូក “ទស្សនៈទៅលើកន្លែងប្រតិបត្តិព្រះធម៌” ស្រេចទៅហើយ។កន្លែងប្រតិបត្តិព្រះធម៌(ដូជោ)មិនមែនសំដៅទៅត្រឹមតែព្រះវិហារ ឬវត្តរបស់យើង តែប៉ុណ្ណោះទេក៏ប៉ុន្តែជាផ្ទះ ជាកន្លែងធ្វើការ សាលារៀន សហគមន៍មូលដ្ឋាន និងកន្លែងផ្សេងទៀតដែលយើងរស់នៅ ពោលគឺថាកន្លែងដែលយើងមានវត្តមាន សុទ្ធតែជាដូជោដែលយើងអាចដុសខាត់បេះដូងនិងគំនិតរបស់យើង។

មិនត្រឹមតែក្នុងអំឡុងពេលនៃការរាតត្បាតនៃកូវីដ១៩ប៉ុណ្ណោះទេ ប៉ុន្តែនៅពេលណាក៏ដោយ ពេលនេះ ទីនេះគឺជាដូជោ (Dojo) ឬកន្លែងសម្រាប់ស្វែងរកមាគ៌ារបស់យើង។ ការយល់ហើយធ្វើដំណើរតាមមាគ៌ានៃការប្រតិបត្តិព្រះពុទ្ធសាសនានេះហើយគឺវីរិយៈឬសេចក្ដីព្យាយាមប្រតិបត្តិមាគ៌ាព្រះពុទ្ធ។

មនុស្សជាច្រើននាក់បានរងការប៉ះពាល់ផ្លូវកាយ ហិរញ្ញវត្ថុ និងផ្លូវចិត្តដោយសារជំងឺរាតត្បាតកូវីដ១៩ ហើយមានមនុស្សជាច្រើនមានការលំបាកក្នុងការដកខ្លួនចាកចេញពីសេចក្តីបារម្ភនៃគ្រោះមហន្តរាយ ហើយមានសេចក្តីព្រួយបារម្ភពីអនាគតកាលរបស់ខ្លួន។

"មនុស្សយើងមិនសំចតនៅនឹងថ្កល់ត្រឹមតែការពិតក្នុងបច្ចុប្បន្ននេះទេ ក៏ប៉ុន្តែស្វែងរកអ្វីដែលខ្ពស់គ្មានទីបញ្ចប់ អ្វីមួយដែលមានតម្លៃ អ្វីមួយដែលអស្ចារ្យ អ្វីមួយដែលនាំឱ្យកើតមានឡើងនូវទឹកចិត្តគោរពកោតខ្លាច។ នៅពេលដែលទឹកចិត្តនៃការគោរពកោតខ្លាចនេះរីកចម្រើន យើងក៏ក្រឡេកមើលមកស្ថានភាពតូចទាបរបស់យើងនៅក្នុងការពិត ហើយក៏កើតមានសេចក្ដីខ្មាសអៀន។ អ្វីដែលសំខាន់បំផុតសម្រាប់មនុស្សជាតិក្នុងការរីកចម្រើននិងភាពប្រសើរឡើងគឺការអភិវឌ្ឍទឹកចិត្តគោរពនិងស្គាល់ការអៀនខ្មាស"។

## អភិវឌ្ឍបេះដូងគោរពកោតខ្លាច និងស្គាល់ភាពអាម៉ាស់គឺជាអ្វីដែលសំខាន់បំផុតសម្រាប់ការរីកចម្រើន និងការកែលម្អរបស់មនុស្ស។

"រៀមច្បង" នៃគោលការណ៍នេះគឺលោក យ៉ាស៊ុអូកា ម៉ាសាហ៊ីរ៉ូ Masahiro Yasuoka ដែលគេស្គាល់ថាជាអ្នកប្រាជ្ញនៃទស្សនវិជ្ជាបូព៌ា និងទស្សនវិជ្ជានយោបាយ។

មនុស្សជាតិបានអភិវឌ្ឍបេះដូងរបស់ខ្លួនក្នុងរយៈពេលរាប់លានឆ្នាំដ៏យូរ ហើយនៅទីបំផុតក៏បានទទួលនូវភាពវៃឆ្លាត និងការយល់ដឹង ដែលពួកគេបានចាប់ផ្តើមបញ្ចេញជាភាសា និងអក្សរ។ មានភាពខុសប្លែកគ្នាជាច្រើនរវាងមនុស្ស និងសត្វដទៃទៀត ប៉ុន្តែអ្វីដែលខុសគ្នាបំផុតនោះគឺថាមនុស្សមាន"ការគោរព" និង"ការអៀនខ្មាស"។

បេះដូងនៃការគោរព គឺជាបេះដូងដែលមិននៅចតស្ងៀមទ្រឹងនៅត្រឹមតែការពិតនៅក្នុងបច្ចុប្បន្នកាលតែប៉ុណ្ណោះទេក៏ប៉ុន្តែស្វែងរកអ្វីមួយដែលខ្ពស់គ្មានទីបញ្ចប់ មានតម្លៃ និងអស្ចារ្យ ហើយព្យាយាមខិតទៅជិតវា។

ឧទាហរណ៍ បើអ្នកជាសមាជិកនៃសមាគមរីស្សូកូសេកៃនេះ អ្នកនឹងគោរពព្រះពុទ្ធ វន្ទាព្រះអង្គ ឱនក្បាល ហើយសំពះប្រណម្យដោយផ្គុំបាតដៃពីរផ្តួបគ្នា។ ពេលនោះយើងម្នាក់ៗតាំងចិត្តថានឹងធ្វើខ្លួនឱ្យទៅជាបុគ្គលដែលអាចយល់ និងដឹងច្បាស់នូវខ្លឹមសារនៃសេចក្តីប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ហើយយកមកអនុវត្ត ព្រមទាំងបន្តបដិបត្តិព្រះធម៌។ ការបួងសួងមិនមែនដើម្បីប្រាថ្នាឲ្យបំណងឬសេចក្តីសង្ឃឹមរបស់យើងក្លាយជាការពិត ទេ តែជាសេចក្តីបំណងនិងសេចក្តីព្យាយាមដើម្បីឈានឱ្យដល់ស្ថានភាពខ្ពង់ ខ្ពស់ជាងបច្ចុប្បន្ន។

បើនិយាយពីអ្វីដែលឆាប់យល់បំផុតគឺ អ្នកប្រហែលជាស្ទើចសរសើររៀមច្បង ដែលខិតខំប្រតិបត្តិព្រះពុទ្ធសាសនា ហើយតែងតែមានឥរិយាបថទន់ភ្លន់រីករាយ ចិត្តល្អ និងកក់ក្តៅ ហើយអ្នកខិតខំធ្វើឱ្យបានដូចអ្នកទាំងនោះ។

មានមនុស្សជាច្រើនដែលយើងសម្លឹងមើលដើម្បីយកមកធ្វើជាគំរូឬធ្វើជាគោលដៅរបស់យើង រួមមានវរជននៅក្នុងប្រវត្តិសាស្ត្រ អ្នកប្រាជ្ញ ទស្សនវិទូ គ្រូបង្រៀនសិល្បៈឬជំនាញនានា អត្តពលិក និងឥស្សរជនវប្បធម៌ជាដើម។

បំណងប្រាថ្នាសម្រាប់វឌ្ឍនភាព និងការកែលម្អ ការមិនពេញចិត្តចំពោះស្ថានភាពខ្លួនឯងដែលមិនទាន់បានទៅដល់ទីសមរម្យ ហើយចង់ខិតចូលទៅជិតស្ថានភាពដ៏ខ្ពង់ខ្ព ស់តាមដែលអាចធ្វើបាននោះ អាចនិយាយបានថាគឺជាសភាវគតិដែលមនុស្សគ្រប់រូបមាន។ សភាវគតិនេះជាប្រភពនៃការលូតលាស់នៃបេះដូងមនុស្ស។

នៅពេលដែលបេះដូងនៃការគោរពបែបនេះរីកចម្រើនឡើង មនុស្សនឹងក្រឡេកមើលទៅភាពខ្វះខាតរបស់ខ្លួនឯង ហើយមានអារម្ម ណ៍ខ្មាសអៀន។

ប្រសិនបើអ្នករកមើលពាក្យ "ខ្មាស" នៅក្នុងវចនានុក្រមវាមានន័យថា "ដឹងអំពីកំហុសនៃសកម្មភាពរបស់ខ្លួន ពីចំណុចអវិជ្ជមាន ពីកំហុសនៃឥរិយាបទ ឬពីភាពមិនទាន់ពេញលេញ ហើយក៏មានអារម្មណ៍អៀនអន់"។ ជាការពិបាកណាស់ដើម្បីឱ្យដឹងថាខ្លួនឯងកំពុងតែនៅខ្វះអ្វីខ្លះដើម្បីឱ្យបានទៅជាមនុស្សពេញលក្ខណៈ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលយើងបានជួបមនុស្សដែលយើងគោរព ឬនរណាម្នាក់ដែលពូកែ យើងក៏អាចដឹងថាយើងនៅតែគួចខៀវនៅឡើយមិនទាន់បានជាមនុស្សពេញលេញនៅឡើយទេ។ ដោយមានអារម្មណ៍ខ្មាសគេ យើងក៏ដាក់វិន័យខ្លួនឯង ហើយចាប់ផ្តើមខិតខំប្រឹងប្រែង។

ម្យ៉ាងទៀតមានពាក្យថា "អានសៀវភៅ ហើយរាប់អានអ្នកប្រាជ្ញក្នុងអតីតកាល" ដែលមានន័យថាការអានសៀវភៅបុរាណៗអាចធ្វើឱ្យអ្នករៀនចេះដឹងពីអ្នកប្រាជ្ញ ហើយឆ្លុះបញ្ចាំងពីខ្លួនអ្នកតាមរយៈការអាននោះ។

ដូច្នេះហើយ អ្វីដែលសំខាន់បំផុតសម្រាប់មនុស្សក្នុងការរីកចម្រើនគឺការអភិវឌ្ឍន៍បេះដូងនៃការគោរព និងស្គាល់ការអៀនខ្មាស។

ការគោរពនិងការចេះអៀនខ្មាសវាត្រូវតែមានជាប់ជាមួយគ្នាមួយគូជានិច្ចជាកាល។ សាសនា នាំទៅរកការគោរពហើយសីលធម៌នាំទៅរកការចេះអៀនខ្មាស។ ដូច្នេះហើយចាំបាច់ត្រូវយល់យ៉ាងម៉ឺងម៉ាត់ថា សាសនា និងសីលធម៌ មិនមែនជារបស់ដាច់ដោយឡែកពីគ្នានោះទេ ក៏ប៉ុន្តែជារបស់ដែលនៅជាប់ជាមួយគ្នា។

## ខិតខំអប់រំមនុស្ស និងអភិវឌ្ឍបុគ្គលិកលក្ខណៈនៅក្នុងគ្រួសារ ហើយកសាងប្រទេសដ៏ល្អមួយដោយផ្អែកលើប្រពៃណីជប៉ុន។

លើសពីនេះទៅទៀត ខ្ញុំព្រះករុណាអាត្មាភាពបានបង្ហាញពីបញ្ហាសំខាន់ជាបាតគ្រឹះនៅក្នុងគោលការណ៍នៃឆ្នាំនេះ ក៏ដូចជាឆ្នាំមុនដែរគឺផ្តោតសំខាន់ទៅលើតួនាទីប្តីប្រពន្ធឪពុកម្តាយ។ ក្នុងនាមជាឪពុកម្តាយ តើគួរបណ្តុះបណ្តាលបុគ្គលិកលក្ខណៈកូនៗ ព្រមទាំងកុមារនិងយុវជនដែលនឹងបន្តវេនវែកពុនសង្គមនាអនាគតកាលដូចម្តេច រៀបចំគ្រួសារឱ្យមានភាពសុខដុំរមនាចុះសម្រុងគ្នាជាដើមដោយវិធីបែបណា?លើសពីនេះទៅទៀតតើត្រូវធ្វើយ៉ាងណាដើម្បីឱ្យអាចបន្តមរតកប្រពៃណីរបស់ប្រទេសជប៉ុន ដើម្បីបង្កើតប្រទេសដ៏ល្អមួយដោយគំនិតច្នៃប្រឌិតនិងម៉ត់ចត់ ។

អ្វីដែលសំខាន់បំផុតក្នុងការចិញ្ចឹមបីបាច់កុមារតូចៗ ក្មេងជំទង់និងយុវជនគឺការផ្តល់នូវការអប់រំមនុស្ស បណ្តុះបណ្តាលអត្តចរិតដ៏រឹងមាំ និងការបង្កើតលក្ខណៈសុខដុំរមនានៅ

ក្នុងគ្រួសារ ដែលជាអង្គភាពតូចបំផុតនៃសង្គ មដោយយកព្រះពុទ្ធរូប មកធ្វើជាចំណុចកណ្តាល។

ពីមុនខ្ញុំព្រះករុណាអាត្មាភាពបានណែនាំពាក្យមួយឃ្លាថា "ឪពុកចង់ក្លាយជាកម្មវត្ថុនៃការគោរពរបស់កូន ៗ ហើយម្តាយចង់ទៅជាទីស្រឡាញ់របស់កូន ៗ ហេតុផលគឺគ្រួសារគឺជាថ្នាលសម្រាប់បណ្តុះនិងចិញ្ចឹមកូន" ។

គេនិយាយថាកូនៗមានចិត្តគោរពឪពុក និងចាត់ទុកម្តាយជាកម្មវត្ថុនៃសេចក្តីស្រឡាញ់របស់ពួកគេ។ ពួកគេរៀនសូត្រពីអាកប្បកិរិ យារបស់ឪពុកម្តាយពួកគេ ហើយយកតម្រា ប់តាមអ្នកទាំងពីរ។

ដូច្នេះ អ្វីដែលសំខាន់បំផុតសម្រាប់ឪពុកគឺត្រូវមានភាពសក្តិសមនឹងការគោរពរបស់កូន។ សូមកុំផ្តោតខ្លាំងពេកទៅលើការងារនៅក្រុមហ៊ុន  ហើយធ្វេសប្រហែសមិនយកចិត្តទុកដាក់ទៅលើគ្រួសារឬគិតតែពីស្តីបន្ទោសតែម្យ៉ាងមិនបានពិចារណាវែងឆ្ងាយ ឬក៏មានឥរិយាបទមិនសមរម្យក្នុងផ្ទះនៅថ្ងៃសម្រាកពីការងារជាដើម។

រីឯម្តាយក៏តោងតែស្រឡាញ់កូនដោយឥតលក្ខខណ្ឌ ហើយផ្តល់ដល់ពួកគេនូវសេចក្តីស្រឡាញ់និងភាពកក់ក្តៅ។ ក្តីស្រឡាញ់របស់ម្តាយ គឺសូម្បីតែកូនធំពេញវ័យ និងមានអាជីពជោគជ័យហើយក្តី ក៏នៅតែព្រួយបារម្ភ និងសោកសៅព្រមទាំងគិតជានិច្ចថា "តើនៅក្នុងសង្គមខាងក្រៅកូនត្រូវស៊ូទ្រាំនិងលំបាកប៉ុណ្ណា?"

កុមារធំចំរើនវ័យដោយសុខភាពល្អទាំងផ្លូវកាយនិងចិត្ត ជាមួយនឹងឪពុកម្តាយបែបនេះ។

ម្យ៉ាងវិញទៀត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានឧប្បត្តិហេតុជាច្រើនគគ្រួតលើគ្នា ដូចជាការឈ្លានពានរបស់រុស្ស៊ីទៅលើអ៊ុយក្រែន និងការប៉ះទង្គិចគ្នារវាងក្រុមប្រដាប់អាវុធអ៊ីស្រាអែល និងប៉ាឡេស្ទីន ដែលបណ្តាលឱ្យមានអ្នកស្លាប់ និងរបួសជាច្រើននាក់។ ក្រៅពីនេះក៏មានបញ្ហាជាច្រើនទៀតដែរ ដូចជាភាពក្រីក្រទីទ័ល ការប្រែប្រួលនៃអាកាសធាតុ ការបំផ្លិចបំផ្លាញបរិស្ថាន កង្វះខាតទឹក និងស្បៀងអាហារ ព្រមទាំងគ្រោះមហន្តរាយធម្មជាតិជាដើម។

បញ្ហាប្រឈមវាស្មុគស្មាញ និងមិនអាចដោះស្រាយបានក្នុងពេលតែមួយព្រឹកឬមួយយប់ទេ ប៉ុន្តែយើងត្រូវតែគិតពីអ្វីដែលនៅក្បែរខ្លួនរបស់យើងមុនជានិច្ច ហើយឆ្ពោះទៅមុខមួយជំហានមួយជំហានដោយមិនបោះបង់ហើយមិនអស់សង្ឃឹម។

ដូចដែលខ្ញុំព្រះករុណាអាត្មាភាពបាននិយា យមកហើយថា នៅសម័យបុរាណ ប្រទេសជប៉ុនបានកំណត់ឈ្មោះប្រទេសថា "យ៉ាម៉ាតូ" ហើយឧត្តមគតិជាតិគឺរក្សានូវស្មារតី "សន្តិភាពដ៏អស្ចារ្យ" និង "ភាពសុខដុំរមនាដ៏អស្ចារ្យ" តាំងពីដើមរៀងមក។

នៅក្នុងមាត្រាដំបូងនៃរដ្ឋធម្មនុញ្ញដែលមាន 17 មាត្រាព្រះអង្គម្ចាស់សូតុគឺ Shotoku បានដាក់ឃ្លាមួយថា "ភាពសុខដុំរមនាមានតម្លៃណាស់" ។ ខ្ញុំព្រះករុណាអាត្មាភាពជឿថាស្មារតីនេះគឺជាទស្សនៈសាកលនៃសន្តិភាពដែលអាចអនុវត្តបានមិនត្រឹមតែចំពោះប្រទេសជប៉ុនតែប៉ុណ្ណោះទេ ក៏ប៉ុន្តែចំពោះប្រទេសនានា និងគ្រប់តំបន់ទាំងអស់។

វាជាដំណើរដ៏សំខាន់សម្រាប់យើងក្នុងការទទួលយកមរតកទំនៀមទម្លាប់របស់ប្រទេសជប៉ុន ហើយធ្វើឱ្យប្រទេសជប៉ុនក្លាយជាប្រជាជាតិដែលមានសន្តិភាពច្បាស់លាស់ និងផ្សព្វផ្សាយទៅដល់ពិភពលោកបន្តទៀត។

ទន្ទឹមនឹងនោះ យើងក៏ត្រូវប្រើពាក្យសម្តីប្រកបទៅដោយសមានចិត្ត និងប្រតិបត្តិតាមគន្លងព្រះពោធិសត្វ នៅរៀងៗអាយខ្លួន ដូចជានៅកន្លែងធ្វើការ សាលារៀន សហគមន៍ ឬនៅផ្ទះជាដើម។ ចូរបន្តធ្វើបែបនេះឲ្យបានខ្ជាប់ខ្ជួន ទោះបីគ្មានអ្នកណាឲ្យតម្លៃក៏ដោយ។

មានសុភាសិតមួយចែងថា "ពន្លឺមួយបំភ្លឺជ្រុង មួយហើយពន្លឺមួយម៉ឺនបំភ្លឺពិភពលោកទាំង មូល" （Ichitoshosumi Manto Hensho）។ "ពន្លឺមួយបំភ្លឺជ្រុងមួយ" （Ichito shosu-

mi ） មានន័យថាមនុស្សម្នាក់ក្លាយជាចង្កៀងហើយបំភ្លឺជុំវិញខ្លួន។រីឯ" ពន្លឺមួយម៉ឺនបំភ្លឺពិភពលោកទាំងមូល"（Manto Hensho） មានន័យថា ពន្លឺមួយប្រមូលផ្តុំគ្នាបង្កើតជាពន្លឺមួយម៉ឺនអាចបំភ្លឺពិភពលោកទាំងមូលឱ្យភ្លឺបាន។

នៅក្នុងដំណើរបែបនេះយើងគោងតែបោះជំហានពីខ្លួនឯងជាមុនសិន។

ក្នុងជីវិត យើងអាចជួបប្រទះនឹងព្រឹត្តិការណ៍ដែលលំបាកស្មានមិនដល់។ យ៉ាងណាមិញ វាច្បាស់ណាស់ថាដោយសារតែមានទុក្ខវេទនា និងសេចក្តីសោកសៅទើបមនុស្សអាចដាស់បេះដូងព្រះពោធិសត្វឱ្យក្រោកឡើងដើម្បីឱ្យអាចជម្នះលើភាពលំបាកនោះបាន។ យើងគោងតែចាត់ទុកវាថាជា"ឱកាសសម្រា ប់ធ្វើឱ្យចិត្តរបស់យើងមានការលូតលាស់ និងជាឱកាសសម្រាប់ធ្វើឱ្យចិត្តរបស់យើងវិវត្តទៅមុខ□ ហើយខិតខំឱ្យអស់ពីចិត្តផ្តល់សមានចិត្តទៅលើមនុស្ស និងអ្វីៗដែលនៅចំពោះមុខយើង - នេះគឺជាស្មារតី"កន្លែងដែលយើងកំពុងតែមានវត្តមាននេះគឺជាកន្លែងប្រតិបត្តិព្រះធម៌ （Sokuze Dojo）” ហើយវាគ្មានអ្វីក្រៅពីការភ្ជួរស្រែបេះដូង នោះទេ។

ខ្ញុំព្រះករុណាអាត្មាភាពសង្ឃឹមយ៉ាងមុះមុតថា យើងម្នាក់ៗនឹងបន្តស្វែងរកអ្វីដែលខ្ពស់ជាង និងធំជាងនេះ ហើយប្រើប្រាស់ចំណុចខ្វះខាតរបស់យើងផ្ទាល់សម្រាប់ពន្លឿន និងកែលម្អដំណើរការមួយជំហានម្តងៗ។

ដកស្រង់ចេញពីកាសែតកូសេលេខចុងឆ្នាំ២០២៣ចេញផ្សាយថ្ងៃទី២៥ខែធ្នូ